# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ អំពើហឹង្សាប្រើទឹកអាស៊ីដ ។

website ៖ www.hoksavann.org

ថ្ងៃទី២១ ឧសភា ២០០៩



ព្រះពុទ្ធសាសនាសំដែង កុំឲ្យមនុស្សបៀតបៀនគ្នា ដោយឲ្យយកខ្លួនជាគ្រឿងឧបមាថា ខ្លួនស្រឡាញ់សេចក្តីសុខ ស្អប់សេចក្តីទុក្ខ ស្រឡាញ់ជីវិត មិនចង់ឲ្យអ្នកដទៃបៀតបៀនខ្លួនយ៉ាងណា អ្នកដទៃទៀតក៏មានបំណងនេះដូចគ្នា ដូច្នេះមិនត្រូវបៀតបៀនគ្នាឡើយ ។ ដើម្បីសុខសន្តិភាពក្នុងសង្គមមនុស្ស បើមានបញ្ហាណាមួយកើតឡើង គប្បីដោះស្រាយដោយសន្តិវិធី ជៀសវាងអំពើហឹង្សាគ្រប់យ៉ាង ។

នៅប្រទេសកម្ពុជា មានអំពើហឹង្សាមួយគួរឲ្យរន្ធត់ គឺការវាយប្រហារដោយប្រើទឹកអាស៊ីដ ។ តាមស្ថិតិ ក្នុងអំឡុង៥ឆ្នាំកន្លងផុតទៅ ការជះទឹកអាស៊ីដដាក់គ្នាមានចំនួនជិត១០០ករណី ។ មូលហេតុដែលនាំឲ្យមានការជះទឹកអាស៊ីដនេះ ភាគច្រើនបណ្តាលមកពីស្នេហាពុំប្រក្រតីខុសគន្លងធម៌ ។ បុរសល្មោភកាមដែលមានភរិយារួចហើយ ភាគច្រើនអ្នកមានបណ្តាស័ក្តិ និងអ្នកសម្បូណ៌ដុល្លារបាន ទៅរកស្ត្រីដទៃទៀត ទោះបីស្ត្រីដែលខ្លួនស្រឡាញ់នោះជាភរិយារបស់គេ និងជាកូនស្រី ដែលមិនបានអនុញ្ញាតពីឪពុកម្តាយ និងមិនមានការយល់ព្រមពីសាមីខ្លួនក៏ដោយ ដោយវិធីល្បួងលោមនិងការគំរាមកំហែង ។ ស្ត្រីទាំងនោះត្រូវរងគ្រោះដោយការប្រច័ណ្ឌរបស់ស្ត្រីជាប្រពន្ធដើម ។ ការជះទឹកអាស៊ីដ ជាវិធីមួយដែលភរិយាដើមយកមកប្រើចំពោះស្ត្រីដែលជាកំណាន់ចិត្តរបស់ប្តីខ្លួន ។ ទឹកអាស៊ីដដែលភរិយាដើមបានជួលគេឲ្យជះទៅស្ត្រីទាំងនោះ បានធ្វើឲ្យស្បែករប-

ស់ស្ត្រីរងគ្រោះ រលេះរលួយដូចត្រីដែលគេអាំងលើភ្លើងគួរឲ្យរន្ធត់ ដោយបំណងរបស់ស្ត្រីប្រពន្ធដើម ធ្វើយ៉ាងណាឲ្យស្ត្រីនោះ បើមិនស្លាប់ក៏ធ្វើឲ្យស្ត្រីនោះពិការខូចសម្ផស្សដែរ ។ ស្ត្រីអ្នករងគ្រោះមួយភាគជាតារាកាខារអូខេ និងតារាចំរៀង ។ អ្នករងគ្រោះមិនបានទទួលយុត្តិធម៌ឡើយ ដោយរដ្ឋមិនបានចាប់អ្នកប្រព្រឹត្តអំពើឧក្រិដ្ឋទាំងនោះមកកាត់ទោស ។

ស្ត្រីជាប្រពន្ធដើមមានការភ័ន្តច្រឡំ ព្រោះពុំមែនជាកំហុសរបស់ស្ត្រីកំណាន់ចិត្តនោះទេ គឺជាកំហុសប្តីរបស់ខ្លួនដែលទៅលួងលោមនិងគំរាមកំហែងគេ ។ ស្ត្រីអ្នករងគ្រោះបានចាញ់បោកការលួងលោមរបស់បុរសខិលខូច និងស្ត្រីមួយភាគមានការភ័យភិតពីការគំរាមកំហែងដល់ជីវិត ដែលមិនអាចមានអ្វីជួយបានក៏ធ្វើតាមជនពាលដើម្បីរក្សាជីវិត ។ ដូច្នេះស្ត្រីទាំងនេះជាអ្នករងគ្រោះ មិនត្រូវប្រពន្ធដើមធ្វើបាបអ្នករងគ្រោះថែមទៀត ដោយជះទឹកអាស៊ីដបែបនេះឡើយ ។ ប្រពន្ធដើមត្រូវផ្តន្ទាទោសប្តីរបស់ខ្លួន ដែលទៅរំលោភលើសិទ្ធិនៃស្ត្រីដទៃ ដែលជាអ្នកស្លូតត្រង់ ដែលត្រូវប្តីរបស់ខ្លួនរំលោភ នៅពេលដែលប្រព័ន្ធច្បាប់ប្រទេសកម្ពុជានៅទន់ខ្សោយ ។ ស្ត្រីប្រពន្ធដើមត្រូវតែបញ្ឈប់នូវអំពើអមនុស្សធម៌របស់ខ្លួនទៅលើអ្នករងគ្រោះ ព្រោះជាអំពើបាបកម្ម ដែលនឹងមានកម្មពៀរទៅមុខទៀត ។ ផ្លូវរដ្ឋត្រូវតែពង្រឹងប្រព័ន្ធច្បាប់ឲ្យតឹងរ៉ឹង ផ្តន្ទាទោសដល់បុរសដែលរំលោភលើសិទ្ធិស្ត្រី ។ ការវាយប្រហារដោយទឹកអាស៊ីដនេះ កញ្ញាទូច-ស៊ុននិចកញ្ញាពៅ-បញ្ញាពេជ្រជាតារាចម្រៀងត្រូវពិការអស់មួយជីវិត ។ ចំណែកអ្នកស្រីខៀវ-ចិន្តា ទីលំនៅនៅក្រុងភ្នំពេញ អាយុ៣៤ឆ្នាំ មានកូន៣នាក់ ត្រូវពិការខ្វាក់ភ្នែកទាំងសងខាងគួរសង្វេគណាស់ ។ អ្នកស្រីពិសិដ្ឋ-ពិលិកា ជាគ្រូបង្រៀនខាងរបាំ ត្រូវគេលួចបាញ់សម្លាប់ គ្មានរកមុខអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនេះឃើញឡើយ ។ អំពើឧក្រិដ្ឋកម្មខ្លះមកលើស្ត្រី គេសង្ស័យថាអាចទាក់ទងផ្លូវនយោបាយ ពុំមែនផ្លូវស្នេហាទេ ដូចអ្នករងគ្រោះកញ្ញាទូច-ស៊ុននិចជាដើម ។ គេតែងនិយាយស្ទើរតែគ្រប់គ្នាថា ស្ត្រីណារូបស្អាតដូចតារាចំរៀងការាអូខេ បវរកញ្ញាជាប់លេខជាដើម ជាចំណីរបស់អ្នកមានអំណាចបុណ្យស័ក្តិ និងអ្នកមានដុល្លារច្រើន ប្រលោមលួងលោម ឬប្រើអំណាចយកមកធ្វើជាស្រីកំណាន់ចិត្ត ដែលធ្វើឲ្យស្ត្រីទាំងនោះទទួលគ្រោះថ្នាក់ដោយទឹកអាស៊ីដពីភរិយាដើម ។ គេពោល

ថា ខ្មែរមិនជ្រើសរើសបវរកញ្ញាជាការល្អហើយ ព្រោះការជ្រើសរើសបវរកញ្ញា ហាក់ដូចជាជ្រើសរើសស្រីមានរូបស្អាត សំរាប់សេចក្តីសប្បាយរបស់អ្នកមាន អំណាចបុណ្យស័ក្តិ និងអ្នកមានដុល្លារច្រើន យកទៅធ្វើជាស្រីកំណាន់ចិត្ត គឺ ជ្រើសរើសឲ្យអ្នកមានអំណាចទាំងនោះ ។

ក្នុងសិក្ខាបទទី៣នៃសីល៥ គឺកាមេសុមិច្ឆាចារា វេរមណី ប្រែថា ត្រូវវៀរចា កការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ គឺវៀរចាកការលួចប្រពន្ធប្តីកូនអ្នកដទៃ គឺ ជាការគោរពកម្មសិទ្ធិខាងសម្ភស្សរបស់អ្នកដទៃ ។ អំពើហឹង្សាមានការជះទឹក អាស៊ីដដាក់គ្នាជាដើមនេះ មកពីការរំលោភសិទ្ធិខាងផ្លូវភេទនេះឯង ។ ឆ្កួត៣យ៉ាង មានឆ្កួតនឹងស្រីជាដើម ជាអំពើអបាយមុខ ជាប្រធាននៃសេចក្តីវិនាស នាំឲ្យ កើតរោគ នាំឲ្យអស់ទ្រព្យសម្បត្តិ នាំឲ្យខូចកិត្តិយស នាំឲ្យកើតជម្លោះ រហូតឲ្យ កើតអំពើហឹង្សា ។ បើវៀរបាន និងប្រព្រឹត្តតាមធម៌ព្រះពុទ្ធនេះ នឹងមានសេចក្តី ចំរើនក្នុងសង្គមគ្រួសារ និងមានសេចក្តីសុខចំរើនក្នុងប្រទេសជាតិ ។ ព្រោះការ បាត់បង់ទឹកដីខ្មែរមួយភាគកាលពីជំនាន់ដើម ដោយសារគេយកស្រីធ្វើជានុយ។ ច្បាប់ឯកពន្ធភាពដែលរាជរដ្ឋាភិបាលបានស្នើ ហើយរដ្ឋសភាបានអនុម័ត ជា ច្បាប់ល្អ ស្របតាមព្រះពុទ្ធសាសនាថា ប្តីប្រពន្ធត្រូវស្មោះត្រង់នឹងគ្នា មួយនិង មួយ កុំទៅរកស្រីឬប្រុសដទៃទៀត ប៉ុន្តែត្រង់អនុវត្តមានប្រសិទ្ធិភាពឬមិនមាន ប្រសិទ្ធិភាព នោះជាបញ្ហាមួយទៀត ។៚

❄ ❄

❄